D164/3/6

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

*តាមនាមប្រជារាស្ត្រខ្មែរ និងតាមនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី*
*ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម*
*ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ*

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០២/១៩-០៩-២០០៧/អវតក/កសចស (អបជ០៥)

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 12 / NOV / 2009
ម៉ោង (Time/Heure): 14:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: CA.

ចំពោះមុខ: ចៅក្រម ប្រាក់ គឹមសាន, ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម និយ ថុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

កាលបរិច្ឆេទ: ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៩

---

សាធារណៈ

## សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំស្វែងរកភស្តុតាង ដោះបន្ទុក នៅក្នុងឃ្លាំងផ្ទុកឯកសាររួម

---

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date /Date de certification): 12 / NOV / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: CA.

**សហព្រះរាជអាជ្ញា**
ជា លាង
យ៉ែត ចរិយា
William SMITH
ពេជ្រ សម្បត្តិ
Vincent de WILDE d'ESTMAEL

**ជនត្រូវចោទ**
អៀង សារី

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

| | |
|---|---|
| ហុង គឹមសួន | Silke STUDZINSKY |
| ឡោ ជុនធី | Martine JACQUIN |
| នី ចាន់ឌី | Philippe CANONNE |
| គង់ ពិសី | Pierre Olivier SUR |
| យុង ផានិត | Elizabeth RABESANDRATANA |
| គីម ម៉េងឃី | Olivier BAHOUGNE |
| ម៉ុច សុវណ្ណារី | David BLACKMAN |
| ស៊ិន សុវ៉ន | Annie DELAHAIE |
| | Fabienne TRUSSES-NAPROUS |
| | Patrick BEAUDOIN |
| | Marie GUIRAUD |
| | LYMA NGUYEN |

**សហមេធាវីការពារក្តី**
អាង ឧត្តម
Michael G. Karnvas

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ២៥)

លេខ/No: D164/3/6

**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា "អ.វ.ត.ក" បានទទួល "បណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត បដិសេធសំណើរួមរបស់មេធាវីការពារក្តី ស្នើសុំបំពេញកិច្ចស៊ើបសួរ ដើម្បីស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួម (SMD) ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៩" ដែលបានដាក់កាលពីថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៩ ("បណ្តឹងឧទ្ធរណ៍")[១]។ "SMD" គឺជាពាក្យកាត់ដែលប្រើប្រាស់សម្រាប់ពាក្យ Shared Materials Drive ដែលមានន័យថា ឃ្លាំងផ្ទុកឯកសាររួម ដែលជាផ្នែកនៃទិន្នន័យអេឡិចត្រូនិចដែលមាននៅ អ.វ.ត.ក។

## I. **សាវតានីតិវិធី**

១. នៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៩ សហចៅក្រមស៊ើបអង្កេតបានចេញដីកាសម្រេចរបស់ខ្លួនលើសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរ ដើម្បីស្វែងរកភស្តុតាងដោះបន្ទុកដែលមាននៅក្នុងឃ្លាំងផ្ទុកឯកសាររួម ("ដីកាសម្រេច")[២] ដែលដីកានេះបានបដិសេធចោលសំណើដាក់រួមគ្នាដោយសហមេធាវីការពារក្តី អៀង ធីរិទ្ធ, អៀង សារី និង នួន ជា នៅថ្ងៃទី២០ ខែមេសា ឆ្នាំ២០០៩ ("សំណើសុំ")[៣]។

២. នៅថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៩ សហមេធាវីការពារក្តីរបស់ អៀង សារី បានជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍[៤] និងនៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៩ សហមេធាវីការពារក្តីបានដាក់សារណាបណ្តឹងឧទ្ធរណ៍របស់ខ្លួន។

---

[១] បណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតបដិសេធសំណើរួមរបស់មេធាវីការពារក្តី ស្នើសុំបំពេញកិច្ចស៊ើបសួរ ដើម្បីស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួម ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៩ D 164/3/1។

[២] ដីកាសម្រេចលើសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរ ដើម្បីស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងទុកឯកសាររួម (SMD/Shared Materials Drive), ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៩, ឯកសារ D164/2។

[៣] សំណើរួមជាបន្ទាន់របស់មេធាវីការពារស្នើសុំឲ្យបំពេញកិច្ចស៊ើបសួរដើម្បីស្វែងរកភស្តុតាងដោះបន្ទុក ដែលផ្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួម ថ្ងៃទី២០ ខែមេសា ឆ្នាំ២០០៩, D164។

[៤] សៀវភៅចុះបណ្តឹងឧទ្ធរណ៍ ថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៩ D164/6។ សៀវភៅចុះបណ្តឹងឧទ្ធរណ៍ ថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៩ D164/4។ សៀវភៅចុះបណ្តឹងឧទ្ធរណ៍ ថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៩ D164/5។



PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRELIMINAIRE

៣. នៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៩ សហព្រះរាជអាជ្ញាបានដាក់ចម្លើយតបរបស់ខ្លួន[៥]។ សហព្រះរាជអាជ្ញាស្នើសុំឱ្យអង្គបុរេជំនុំជម្រះ សម្រេចលើបណ្តឹងឧទ្ធរណ៍ដោយផ្អែកលើមូលដ្ឋាននៃការដាក់សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរតែប៉ុណ្ណោះ[៦]។

៤. នៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០០៩ អង្គបុរេជំនុំជម្រះបានសម្រេចកំណត់បណ្តឹងឧទ្ធរណ៍ដោយផ្អែកលើមូលដ្ឋានសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរតែប៉ុណ្ណោះ និងបង្គាប់ឱ្យភាគីនានា ឆ្លើយតបនៅក្នុងរយៈពេលកំណត់ ដែលមានចែងនៅក្នុងមាត្រា៨.៤នៃសេចក្តីណែនាំអនុវត្ត អវតក/០១/២០០៧/វិសោធនកម្មលើកទី៤[៧]។

៥. នៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០៩ សហមេធាវីការពារក្តី អៀង សារី បានដាក់សេចក្តីឆ្លើយតបរបស់ខ្លួន[៨]។

## II. សារណារបស់ភាគីនានា

៦. សារណាបណ្តឹងឧទ្ធរណ៍សម្រេចយកអង្គហេតុ និងទឡ្ហីករណ៍នានា ដែលលើកឡើងនៅក្នុង "បណ្តឹងឧទ្ធរណ៍រួមរបស់មេធាវីការពារក្តី ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស ស្តីពីសំណើសុំបំពេញកិច្ចស៊ើបសួរ ដើម្បីស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុក

---

[៥] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ, នួន ជា, ខៀវ សំផន និងអៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ដែលបដិសេធសំណើរួមរបស់មេធាវីការពារក្តី សុំឱ្យបំពេញកិច្ចស៊ើបសួរ ដើម្បីស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួមក្នុងកុំព្យូទ័រ, ថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៩, D164/4/2 ("ចម្លើយតប")។

[៦] ចម្លើយតប កថាខណ្ឌ១២-១៦។

[៧] សេចក្តីសម្រេចលើ "សំណើសុំបើកសវនាការសួរដេញដោលផ្ទាល់មាត់" លើបណ្តឹងឧទ្ធរណ៍ អបជ២៤ និង អបជ២៥, ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០០៩, ឯកសារ D164/4/3។

[៨] សេចក្តីឆ្លើយតបរបស់លោក អៀង សារី ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត បដិសេធសំណើរួមរបស់មេធាវីការពារក្តីសុំឱ្យបំពេញកិច្ចស៊ើបសួរ ដើម្បីស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួម ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០៩ D164/4/4 ("សេចក្តីឆ្លើយតប")។

00402870



ឯកសាររួម (SMD) ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៩"[៩] ដែលដាក់នៅថ្ងៃជាមួយគ្នា ដោយមេធាវីការពារក្តីរបស់ អៀង ធីរិទ្ធ, នួន ជា និង ខៀវ សំផន ("បណ្តឹងឧទ្ធរណ៍រួម") និងបានលើកឡើងនូវមូលហេតុពីរទៀតនៅក្នុងសារណាបន្ថែមរបស់ខ្លួន។

៧. តាមរយៈបណ្តឹងឧទ្ធរណ៍របស់ខ្លួន សហមេធាវីការពារក្តី អៀង សារី ស្នើសុំអង្គបុរេជំនុំជម្រះ (i) ច្រានចោលដីកាសម្រេច (ii) "ប្រកាសថា គោលការណ៍នៃភាពគ្រប់គ្រាន់នៃភស្តុតាងដែលគាំទ្រដោយ [ក.ស.ច.ស] ត្រូវតែផ្តើមការស៊ើបអង្កេតស្វែងរក និងពិចារណាលើភស្តុតាងដោះបន្ទុកទាំងអស់ នៅពេលសម្រេចថាតើត្រូវចោទប្រកាន់ជនត្រូវចោទក្រោមវិធាន ៦៧(១) ឬយ៉ាងណា" (iii) បង្គាប់ឱ្យ ក.ស.ច.ស ពិនិត្យឡើងវិញនូវឯកសារទាំងអស់ដែលបានដាក់នៅក្នុង SMD (iv) បង្គាប់ឱ្យ ក.ស.ច.ស ធ្វើរបាយការណ៍លម្អិតគ្រប់គ្រាន់នៃការវិភាគរបស់ខ្លួន និង (v) បង្គាប់ឱ្យ ក.ស.ច.ស ផ្តល់បញ្ជីភស្តុតាងដោះបន្ទុកដែលមាននៅក្នុង SMD[១០]។

៨. បណ្តឹងឧទ្ធរណ៍រួមបានលើកទឡ្ហីករណ៍ថា (i) តាមរយៈការអនុម័តវិធីសាស្ត្រដែលសហចៅក្រមស៊ើបអង្កេតត្រូវការ គ្រាន់តែសម្រាប់ស្វែងរកភស្តុតាងឱ្យបានគ្រប់គ្រាន់ក្នុងការចោទប្រកាន់ជនត្រូវចោទ មុនពេលបញ្ចប់ការស៊ើបអង្កេតរបស់ខ្លួននោះ សហចៅក្រមស៊ើបអង្កេតបានរំលោភលើកាតព្វកិច្ចរបស់ខ្លួនក្នុងការស្វែងរកភស្តុតាងដោះបន្ទុក ដែលមានចែងនៅក្នុងវិធាន៥៥(៥) នៃវិធានផ្ទៃក្នុងរួចទៅហើយ[១១] (ii) ឯកសារដែលមាននៅក្នុងSMDស្ថិតនៅក្នុងប្រភេទ "ឯកសារដទៃទៀតដែលចាត់ទុកជាភស្តុតាង" នៅក្នុងវិធាន៥៣(២) នៃវិធានផ្ទៃក្នុង ហេតុដូច្នេះសហចៅក្រមស៊ើបអង្កេតមានតួនាទីវិភាគភស្តុតាងទាំងនោះ[១២] (iii) សហចៅក្រមស៊ើបអង្កេតមិនអាចបដិសេធមិនបំពេញកាតព្វកិច្ចរបស់ខ្លួនក្នុងការស៊ើបអង្កេតឯកសារនៅក្នុងSMD ដោយសំអាងថា ការធ្វើបែបបនេះ គឺដើម្បី

---

[៩] សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/កសចស (អបជ២៤) បណ្តឹងឧទ្ធរណ៍រួមរបស់មេធាវីការពារក្តីប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស ស្តីពីសំណើសុំបំពេញកិច្ចស៊ើបសួរ ដើម្បីស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួម (SMD) ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៩ នៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៩ D164/4/1 ("សារណាឧទ្ធរណ៍រួម")។

[១០] សារណាឧទ្ធរណ៍ ទំព័រ៥-៦។

[១១] បណ្តឹងឧទ្ធរណ៍រួម កថាខណ្ឌ១៨-២១។

[១២] បណ្តឹងឧទ្ធរណ៍រួម កថាខណ្ឌ២២-២៨។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

កុំឱ្យរំលោភលើសិទ្ធិរបស់ជនត្រូវចោទ ក្នុងការទទួលបានការជម្រះក្តីដោយគ្មានការពន្យារពេលនោះទេ។ ការយកសិទ្ធិរបស់ជនត្រូវចោទមកសំអាងបែបនេះ រំលោភលើវិធាន២១ និងវិធាន៥៥(៥) នៃវិធានផ្ទៃក្នុង[១៣] និង(iv) សំណើសុំមានភាពច្បាស់លាស់គ្រប់គ្រាន់[១៤]។

៩. នៅក្នុងសារណាបណ្តឹងឧទ្ធរណ៍របស់ខ្លួន សហមេធាវីការពារក្តី អៀង សារី លើកទឡ្ហីករណ៍បន្ថែមថា មិនមានគោលការណ៍ភាពគ្រប់គ្រាន់នៃភស្តុតាង នៅក្នុងប្រព័ន្ធច្បាប់ស៊ីវិលទេ ហើយសហចៅក្រមស៊ើបអង្កេតភ័ន្តច្រឡំថា លក្ខខណ្ឌនេះអនុញ្ញាតឱ្យបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ និងបញ្ចប់ការស៊ើបអង្កេត[១៥]។ សហមេធាវីការពារក្តីតវ៉ាថា ជនត្រូវចោទមិនត្រូវបង្ខំឱ្យជ្រើសរើសរវាងសិទ្ធិទទួលការជំនុំជម្រះ ដោយគ្មានការពន្យារពេលមិនត្រឹមត្រូវ និងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ទេ[១៦] ហើយសហមេធាវីការពារក្តីបានភ្ជាប់លិខិតបោះបង់សិទ្ធិមកជាមួយនឹងបណ្តឹងឧទ្ធរណ៍នេះ ដែលលិខិតនោះចុះហត្ថលេខាដោយជនត្រូវចោទ នៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៩ "ដោយលះបង់សិទ្ធិរបស់គាត់ ក្នុងការទទួលបានការជម្រះក្តីដោយគ្មានការពន្យារពេលមិនត្រឹមត្រូវសម្រាប់រយៈពេលមួយខែ ដើម្បីឱ្យ ក.ស.ច.ស ចាត់វិធានការស៊ើបសួរ ដែលត្រូវបានស្នើសុំ"[១៧]។

១០. នៅក្នុងចម្លើយតបរបស់ខ្លួន សហព្រះរាជអាជ្ញាបានសន្និដ្ឋានថា សហចៅក្រមស៊ើបអង្កេតបានបដិសេធយ៉ាងត្រឹមត្រូវលើសំណើសុំនេះ និងស្នើសុំឱ្យអង្គបុរេជំនុំជម្រះបដិសេធបណ្តឹងឧទ្ធរណ៍ចោល ប៉ុន្តែសហព្រះរាជអាជ្ញាបានសន្និដ្ឋានថា វាអាចជាការសមស្របសម្រាប់អង្គបុរេជំនុំជម្រះ ក្នុងការដាក់ជំនួស ឬបន្ថែមអំណះអំណាងទៅលើដីកាសម្រេច ដោយយោងទៅលើ "គោលការណ៍នៃភាពគ្រប់គ្រាន់" តាមរយៈការស្នើសុំរបស់ភាគីនៅក្នុងសេចក្តីសន្និដ្ឋាននៃចម្លើយតបរបស់ខ្លួន[១៨]។

---

[១៣] បណ្តឹងឧទ្ធរណ៍រួម កថាខណ្ឌ៣៤។

[១៤] បណ្តឹងឧទ្ធរណ៍រួម កថាខណ្ឌ៣៥-៤២។

[១៥] សារណាឧទ្ធរណ៍ កថាខណ្ឌ៣-១០។

[១៦] សារណាឧទ្ធរណ៍ កថាខណ្ឌ១១-១២។

[១៧] សារណាឧទ្ធរណ៍ កថាខណ្ឌ១២។

[១៨] ចម្លើយតប កថាខណ្ឌ៥៨ និង៥៩។

១១. ជាពិសេស សហព្រះរាជអាជ្ញាតវ៉ាថា សហចៅក្រមស៊ើបអង្កេតភ័ន្តច្រឡំក្នុងការលើកឡើងនូវសេចក្តីថ្លែងមិនត្រឹមត្រូវដែលថ្លែងថា កិច្ចស៊ើបសួររបស់តុលាការត្រូវបញ្ចប់ភ្លាមបន្ទាប់ពីមានភស្តុតាងគ្រប់គ្រាន់សម្រាប់ចោទប្រកាន់ និងថា ភាពគ្រប់គ្រាន់នៃភស្តុតាងគឺវាគ្រប់គ្រាន់ទៅហើយ ដោយមិនចាំបាច់មានភស្តុតាងទាំងអស់នោះទេ[១៩]។ សហព្រះរាជអាជ្ញាសន្និដ្ឋានថា តាមការពិចារណារនៅក្នុងបរិបទរបស់ខ្លួន ការអនុវត្តគោលការណ៍នេះមិនមានលក្ខណៈទូលំទូលាយសម្រាប់ធ្វើយុត្តិកម្ម ចំពោះការបដិសេធដីកាសម្រេចណាមួយនោះទេ[២០] ដោយសារតែសហចៅក្រមស៊ើបអង្កេត បានធ្វើការបកស្រាយត្រឹមត្រូវអំពីកាតព្វកិច្ចរបស់ខ្លួន ក្នុងការស្វែងរកប្រភពឯកសារទាំងអស់ ដើម្បីស្រាវជ្រាវរកភស្តុតាងដាក់បន្ទុក និងភស្តុតាងដោះបន្ទុក ហើយលក្ខខណ្ឌដែលស្នើសុំបំពេញកិច្ចស៊ើបសួរ ត្រូវតែមានភាពពាក់ព័ន្ធ និងច្បាស់លាស់គ្រប់គ្រាន់[២១]។ សហព្រះរាជអាជ្ញាបានសន្និដ្ឋានបន្ថែមថា សហចៅក្រមស៊ើបអង្កេតមិនមានកាតព្វកិច្ចវិភាគឯកសារនៅក្នុងSMDទេ ដោយសារតែឯកសារទាំងនោះ មិនត្រូវបានដាក់ជាមួយគ្នានឹងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ដែលគាំទ្រដល់ការចោទប្រកាន់ទាំងឡាយដែលមាននៅក្នុងដីកានោះ ឬឯកសារទាំងនោះមិនត្រូវបានដាក់បញ្ចូលជាផ្នែកនៃសំណុំរឿងជាបន្តបន្ទាប់មកទៀត[២២]។

១២. បន្ថែមលើការផ្តល់មតិយោបល់ទៅលើសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ក្នុងការសម្រេចលើបណ្តឹងឧទ្ធរណ៍ ដោយផ្អែកលើមូលដ្ឋាននៃសារណាជាលាយលក្ខណ៍អក្សរ[២៣] នៅក្នុងចម្លើយតបរបស់ខ្លួន សហមេធាវីការពារក្តី អៀង សារី លើកឡើងជាថ្មីនូវការជំទាស់របស់ខ្លួន ទៅនឹងលក្ខខណ្ឌនៃភាពច្បាស់លាស់សម្រាប់សំណើសុំបំពេញកិច្ចស៊ើបសួរ និងលើកឡើងថា “[សហព្រះរាជអាជ្ញា] មិនអាចចង្អុលបង្ហាញអំពីអំណះអំណាងច្បាស់លាស់របស់[សហចៅក្រមស៊ើបអង្កេត] ដែលលើកឡើងថា សហចៅក្រមស៊ើបអង្កេតត្រូវតែស៊ើបអង្កេត រហូតដល់មានភស្តុតាងគ្រប់គ្រាន់ ដើម្បីសម្រេចចោទប្រកាន់”[២៤]។

[១៩] ចម្លើយតប កថាខណ្ឌ២៨។

[២០] ចម្លើយតប កថាខណ្ឌ២៨។

[២១] ចម្លើយតប កថាខណ្ឌ ២៦។

[២២] ចម្លើយតប កថាខណ្ឌ៣៤។

[២៣] សេចក្តីឆ្លើយតប កថាខណ្ឌ១។

[២៤] សេចក្តីឆ្លើយតប កថាខណ្ឌ៦។

សហមេធាវីការពារក្តីក៏បានលើកឡើងថា ដីកាសម្រេច "បង្កប់ន័យយ៉ាងខ្លាំងថា [សហចៅក្រមស៊ើបអង្កេត] កំពុងយកជាសំអាងមិនត្រឹមត្រូវទៅលើសិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេលមិនត្រឹមត្រូវ ដើម្បីបដិសេធសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរដែលមានភាពស្របច្បាប់"[២៥]។ ជាចុងក្រោយ សហមេធាវីការពារក្តីលើកឡើងថា ដីកាសម្រេច មិនបានដោះស្រាយនូវការលះបង់សិទ្ធិ ដែលចុះហត្ថលេខាដោយជនត្រូវចោទទេ[២៦]។

## III. ភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍

១៣. នៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៩ សហចៅក្រមស៊ើបអង្កេត បានចេញដីកាសម្រេចរបស់ខ្លួន ដែលត្រូវបានជូនដំណឹងដល់ភាគីនានាកាលពីថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៩។ សហមេធាវីការពារក្តីជនត្រូវចោទ បានជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ នៅថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៩ ដោយអនុលោមតាមវិធាន៧៥(១) នៃវិធានផ្ទៃក្នុង។ សារណាបណ្តឹងឧទ្ធរណ៍ត្រូវបានដាក់នៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៩ នៅក្នុងរយៈពេលកំណត់ ដូចមានចែងនៅក្នុងវិធាន៧៥(៣) នៃវិធានផ្ទៃក្នុង។

១៤. សារណាបណ្តឹងឧទ្ធរណ៍រួមបានលើកឡើងថា បណ្តឹងឧទ្ធរណ៍អាចទទួលយកបានក្រោមវិធាន៧៤(៣)(ខ) នៃវិធានផ្ទៃក្នុង ដោយសារតែបណ្តឹងឧទ្ធរណ៍ត្រូវបានដាក់ប្រឆាំងនឹងដីកាសម្រេចបដិសេធសំណើសុំបំពេញកិច្ចស៊ើបសួរ។

១៥. អង្គបុរេជំនុំជម្រះសង្កេតឃើញថា អនុលោមតាមវិធាន៧៤(៣)(ខ) នៃវិធានផ្ទៃក្នុង ជនត្រូវចោទអាចប្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចបដិសេធសំណើសុំបំពេញកិច្ចស៊ើបសួររបស់សហចៅក្រមស៊ើបអង្កេត ដូចដែលមានចែងនៅក្នុងវិធានផ្ទៃក្នុង។

១៦. វិធាន៥៨(៦) នៃវិធានផ្ទៃក្នុង ដែលពាក់ព័ន្ធកាន់តែច្បាស់ជាមួយនឹងសំណើសុំបំពេញកិច្ចស៊ើបសួររបស់ជនត្រូវចោទ បានចែងថា៖

---

[២៥] សេចក្តីឆ្លើយតប កថាខណ្ឌ១១។

[២៦] សេចក្តីឆ្លើយតប កថាខណ្ឌ១២។



អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

"៦. ក្នុងអំឡុងពេលស៊ើបសួរ ជនត្រូវចោទអាចស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតសួរចម្លើយខ្លួន ស្តាប់ចម្លើយសាក្សី ចុះទៅដល់ទីកន្លែងកើតហេតុ បង្គាប់ឱ្យធ្វើកោសល្យវិច័យ ឬប្រមូលយកភស្តុតាងដទៃទៀត។ សំណើនេះត្រូវធ្វើជាលាយលក្ខណ៍អក្សរដោយមានបញ្ជាក់មូលហេតុពិតប្រាកដ។ ប្រសិនបើសហចៅក្រមស៊ើបអង្កេតមិនយល់ព្រមតាមសំណើនេះទេ សហចៅក្រមស៊ើបអង្កេតត្រូវចេញដីកាបដិសេធឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន និងនៅគ្រប់ករណីទាំងអស់ ត្រូវចេញដីកាបដិសេធនេះនៅមុនពេលបញ្ចប់កិច្ចស៊ើបសួរ។ ដីកាបដិសេធត្រូវមានសំអាងហេតុ។ ជនត្រូវចោទ ត្រូវបានជូនដំណឹងជាបន្ទាន់អំពីដីកាបដិសេធនេះ។ ជនត្រូវចោទ អាចធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកានេះទៅអង្គបុរេជំនុំជម្រះ"។

១៧. អង្គបុរេជំនុំជម្រះកត់សម្គាល់ថា វិធាន៥៥(១០) នៃវិធានផ្ទៃក្នុង ដែលលើកឡើងជាទូទៅនូវសិទ្ធិរបស់ភាគីទាំងអស់ដែលពាក់ព័ន្ធនឹងសំណើសុំបំពេញកិច្ចស៊ើបសួរ ចែងថា៖

"១០. នៅគ្រប់ពេលវេលានៃការស៊ើបសួរ សហព្រះរាជអាជ្ញា ជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណី អាចស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតចេញដីកា ឬបំពេញកិច្ចស៊ើបសួរណាមួយដែលខ្លួនយល់ឃើញថាមានប្រយោជន៍ដល់ការស៊ើបសួរ។ ប្រសិនបើសហចៅក្រមស៊ើបអង្កេតមិនយល់ព្រម សហចៅក្រមស៊ើបអង្កេតត្រូវចេញដីកាបដិសេធឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន ហើយនៅគ្រប់ករណីទាំងអស់ត្រូវចេញដីកានេះឱ្យបានមុនពេលបញ្ចប់កិច្ចស៊ើបសួរ។ ដីកាបដិសេធនេះ ត្រូវមានសំអាងហេតុ ហើយត្រូវជូនដំណឹងដល់ភាគី។ ដីកាបដិសេធនេះបើកផ្លូវប្តឹងឧទ្ធរណ៍"។

១៨. នៅក្នុងសាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចស្តីពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ អង្គបុរេជំនុំជម្រះយល់ឃើញថា "សំណើសុំបំពេញកិច្ចស៊ើបសួរ គួរត្រូវគេបកស្រាយថា ជាសំណើសុំឱ្យសហចៅក្រមស៊ើបអង្កេត ឬអ្នកស៊ើបអង្កេត ឬក៏មន្ត្រីនគរបាលយុត្តិធម៌ តាមរយៈដីកាចាត់ឱ្យសួរជំនួសបំពេញកិច្ចណាមួយ ក្នុងគោលបំណងប្រមូលភស្តុតាង ដែលនាំដល់ការលាតត្រដាងការពិត"[២៧]។

[២៧] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចស្តីពីសិទ្ធិ និង កាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ, ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០៩, ឯកសារ A190/I/20, កថាខណ្ឌ២៨។



អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. * C.E.T.C.

១៩. ចំណុចសំខាន់នៃសំណើ ស្នើសុំថា សហចៅក្រមស៊ើបអង្កេតត្រូវតែវិភាគលើឯកសារនានាដែលការិយាល័យសហព្រះរាជអាជ្ញា និងការិយាល័យសហចៅក្រមស៊ើបអង្កេត មានតាមរយៈSMD ដើម្បីកំណត់ភស្តុតាងដោះបន្ទុកដែលអាចមាន និងជាចុងក្រោយបញ្ចូលភស្តុតាងដោះបន្ទុកទាំងនោះទៅក្នុងសំណុំរឿង។ សហចៅក្រមស៊ើបអង្កេតបានបដិសេធសំណើសុំនេះ ដោយផ្អែកលើអង្គសេចក្តីរបស់វា។ ដោយមិនចាំបាច់វាយតម្លៃភាពពេញលេញតាមលក្ខខណ្ឌនានារបស់សំណើសុំថា វាជាសំណើមានសុពលភាពនិងអង្គសេចក្តីរបស់ខ្លួន អង្គបុរេជំនុំជម្រះយល់ឃើញថា ដោយពិចារណាអំពីគោលបំណងរបស់ខ្លួន សំណើសុំនេះអាចចាត់ទុកជាសំណើសុំបំពេញកិច្ចស៊ើបសួរ។ ដូចនេះ ដីកាសម្រេចបដិសេធសំណើសុំបែបនេះ អាចត្រូវប្តឹងឧទ្ធរណ៍ តាមវិធាន៧៤(៣) នៃវិធានផ្ទៃក្នុង។

២០. ដោយសារមូលហេតុដូចខាងលើនេះ អង្គបុរេជំនុំជម្រះយល់ឃើញថា បណ្តឹងឧទ្ធរណ៍អាចទទួលយកបាន។

## IV. សេចក្តីពិចារណា

### ក. បទដ្ឋាននៃការពិនិត្យឡើងវិញ

២១. អង្គបុរេជំនុំជម្រះសង្កេតឃើញថា សហចៅក្រមស៊ើបអង្កេតមានឆន្ទានុសិទ្ធិទូលំទូលាយនៅពេលសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរ។ នៅក្នុងករណីនេះ វិធាន៥៥(៥) នៃវិធានផ្ទៃក្នុងចែងថា “ក្នុងការដឹកនាំកិច្ចស៊ើបសួរ សហចៅក្រមស៊ើបអង្កេតអាចចាត់វិធានការស៊ើបសួរដែលនាំទៅរកការបង្ហាញការពិត”។ នៅក្នុងសាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នរបស់ជនត្រូវចោទ អៀង ធីរិទ្ធ អង្គបុរេជំនុំជម្រះទទួលស្គាល់ថា សហចៅក្រមស៊ើបអង្កេត “មានឯករាជ្យភាពចំពោះការដឹកនាំកិច្ចស៊ើបសួររបស់ខ្លួន”[២៨]។ ដោយសារការយល់ឃើញបែបនេះ និងដោយសារគ្មានការចែងអំពីលក្ខខណ្ឌតម្រូវច្បាស់លាស់ណាមួយនៅក្នុងវិធានផ្ទៃក្នុង សហចៅក្រមស៊ើប

[២៨] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នរបស់ជនត្រូវចោទ អៀង ធីរិទ្ធ, កថាខណ្ឌ៦៣, យោងទៅលើប្រព័ន្ធរបស់បារាំងដែលត្រូវបានប្រើប្រាស់ដើម្បីបកស្រាយវិធានផ្ទៃក្នុង ៥៥(៥) ជាពិសេស៖ C. Guéry, *Instruction Préparatoire,* Rép. pén. Dalloz, ខែមករា ឆ្នាំ២០០៨, កថាខណ្ឌ៥៧។

អង្កេត មានឥន្ទានុសិទ្ធិក្នុងការសម្រេចលើភាពចាំបាច់ ឬឱកាសក្នុងការសម្រេចបានកិច្ចស៊ើបសួរ ទោះបីជាកិច្ចស៊ើបសួរនោះត្រូវបានស្នើសុំដោយភាគីមួយក្តី[២៩]។ ករណីនេះគ្រាន់តែជាបញ្ហាមួយនៃអង្គហេតុប៉ុណ្ណោះ[៣០]។ និយាយម្យ៉ាងទៀត ភាគីនានាអាចស្នើសុំ ប៉ុន្តែមិនមែនតម្រូវឱ្យសហចៅក្រមស៊ើបអង្កេតបំពេញកិច្ចស៊ើបសួរនោះទេ[៣១]។ វាមានការកត់សម្គាល់បន្ថែមថា ទោះបីជាកិច្ចស៊ើបអង្កេត ត្រូវបានបដិសេធចោល ក្នុងអំឡុងពេលនៃការស៊ើបអង្កេតរបស់តុលាការ ប៉ុន្តែវានៅតែមានលទ្ធភាពដែលថា អង្គជំនុំជម្រះសាលាដំបូងអាចសម្រេចបង្គាប់ឱ្យបំពេញកិច្ចស៊ើបសួរនៅពេលក្រោយ[៣២]។

២២. អង្គបុរេជំនុំជម្រះកត់សម្គាល់ថា កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ និងវិធានផ្ទៃក្នុង មិនមានចែងអំពីបទដ្ឋាននៃការពិនិត្យឡើងវិញនៅពេលទទួលបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចបដិសេធសំណើសុំបំពេញកិច្ចស៊ើបសួរទេ។

២៣. ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់ឱ្យសភាស៊ើបសួរមានយុត្តាធិការ "បង្គាប់ឱ្យធ្វើកិច្ចស៊ើបសួរបំពេញបន្ថែម តាមដែលខ្លួនយល់ឃើញថា មានប្រយោជន៍"[៣៣] និងជាទូទៅផ្តល់អំណាចទូលំទូលាយដល់សភាស៊ើបសួរ នៅពេលទទួលយកបណ្តឹងឧទ្ធរណ៍ ដូចដែលបានលើកឡើងពីមុន ដោយអង្គបុរេជំនុំជម្រះនៅក្នុងសាលដីកាលើបណ្តឹងឧទ្ធរណ៍

---

[២៩] C. Guéry, *Instruction Préparatoire,* Rép. pén. Dalloz, ខែមករា ឆ្នាំ២០០៨, កថាខណ្ឌ៥៦។ Crim. Cass., ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ១៩៩៥, Bull. crim. 1995, no. 272, ទំព័រ ៧៥៩។

[៣០] Crim. Cass., ថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៩៧, Bull. Crim. 1997, no. 118, ទំព័រ ៤០០។ Crim. Cass. ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ១៩៩៥, Bull. crim. 1995, no. 272, ទំព័រ ៧៥៩។

[៣១] F.-L. COSTE, *Chambre de l'instruction,* Rép. pén. Dalloz, ខែធ្នូ ឆ្នាំ២០០៦, កថាខណ្ឌ[illegible]។

[៣២] វិធាន៩៣ នៃវិធានផ្ទៃក្នុង។

[៣៣] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មាត្រា២៦២។

ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នរបស់ជនត្រូវចោទ កាំង ហ្គេកអ៊ាវ ហៅ "ឌុច"[៣៤]។

២៤. អង្គបុរេជំនុំជម្រះសង្កេតឃើញថា វិធានផ្ទៃក្នុងមិនបានផ្ដល់អំណាចឱ្យអង្គបុរេជំនុំជម្រះក្នុងការបង្គាប់ឱ្យបំពេញកិច្ចស៊ើបសួរបន្ថែមទេ ប៉ុន្តែវិធានផ្ទៃក្នុងកំណត់នូវតួនាទីរបស់ខ្លួនក្នុងការសម្រេចលើបណ្ដឹងឧទ្ធរណ៍ ដែលដាក់ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត[៣៥]។ ភាពខុសគ្នាពីក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មានយុត្តិកម្ម ដោយសារប្រភេទពិសេសនៃសំណុំរឿងចំពោះមុខ អ.វ.ត.ក ដែលជាសំណុំរឿងពាក់ព័ន្ធនឹងការស៊ើបអង្កេតក្នុងទំហំធំ និងជាប់ពាក់ព័ន្ធនឹងករណីច្រើនលើសលុប ហើយអង្គបុរេជំនុំជម្រះមិនត្រូវបានបង្កើតឡើង និងមិនត្រូវបានរៀបចំ ដើម្បីដឹកនាំការស៊ើបអង្កេតទេ។ ដោយសារតែសេចក្ដីសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរ គឺជាសេចក្ដីសម្រេចឆន្ទានុសិទ្ធិ ដែលពាក់ព័ន្ធនឹងបញ្ហាអង្គហេតុ អង្គបុរេជំនុំជម្រះយល់ឃើញថា នៅក្នុងសំណុំរឿងពិសេសចំពោះមុខ អ.វ.ត.ក សហចៅក្រមស៊ើបអង្កេត ជាអ្នកមានតួនាទីទូទៅ និងការយល់ដឹងលើសំណុំរឿង គឺជាអ្នកដែលមានលក្ខណៈសម្បត្តិប្រសើរបំផុត ក្នុងការវាយតម្លៃកាលានុវត្តភាពនៃការដឹកនាំកិច្ចស៊ើបសួរដែលស្នើសុំ។ នៅក្នុងកាលៈទេសៈទាំងនេះ វាគឺជារឿងដែលមិនសមស្របសម្រាប់អង្គបុរេជំនុំជម្រះ ធ្វើការជំនួសសហចៅក្រមស៊ើបអង្កេត ក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន នៅពេលសម្រេចលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចបដិសេធសំណើសុំបំពេញកិច្ចស៊ើបសួរ។

២៥. អង្គបុរេជំនុំជម្រះកត់សម្គាល់ថា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការអន្តរជាតិនានាមានវិសាលភាពតូចចង្អៀតណាស់ក្នុងការពិនិត្យឡើងវិញ នៅពេលដោះស្រាយបញ្ហាបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្ដីសម្រេចឆន្ទានុសិទ្ធិរបស់យុត្តាធិការសាលាដំបូង។ នៅក្នុងករណីនេះ អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ("តុលាការយូហ្គោស្លាវី") បានចែងនៅក្នុង "សាលដីកាលើបណ្ដឹង

---

[៣៤] សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្ដោះអាសន្នរបស់ជនត្រូវចោទ កាំង ហ្គេកអ៊ាវ ហៅ "ឌុច" ចុះថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០០០៧, ឯកសារ C5/45, កថាខណ្ឌ៤១។

[៣៥] វិធាន៧៣(ក) នៃវិធានផ្ទៃក្នុង។

សាទុក្ខបន្ទាន់បង្ខំជំទាស់នឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង លើការតែងតាំងមេធាវីការពារក្តី” នៅក្នុងរឿងក្តី *Milosevic តទល់នឹង រដ្ឋអាជ្ញា*[៣៦]៖

“<u>បទដ្ឋាននៃការពិនិត្យឡើងវិញ</u>”

៩. ដូចដែលអង្គជំនុំជម្រះតុលាការកំពូលបានកត់សម្គាល់ពីមុន អង្គជំនុំជម្រះសាលាដំបូងអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួននៅក្នុង “ស្ថានភាពខុសៗគ្នាជាច្រើន ដូចជានៅពេលសម្រេចផ្តន្ទាទោស ការសម្រេចថាតើគួរឬមិនគួរដោះលែងបណ្តោះអាសន្ន បញ្ហាទាក់ទងនឹងការទទួលយកនូវប្រភេទមួយចំនួននៃភស្តុតាង ការវាយតម្លៃភស្តុតាង និង (ជាញឹកញាប់ៗ) ការសម្រេចលើចំណុចនៃការអនុវត្ត ឬនីតិវិធី”។ ការចាត់តាំងមេធាវីរបស់អង្គជំនុំជម្រះសាលាដំបូង ស្ថិតនៅក្នុងប្រភេទមួយនេះនៃសេចក្តីសម្រេច។ការសម្រេចនេះ គឺផ្អែកទៅលើបទពិសោធន៍ប្រចាំថ្ងៃជាក់ស្តែងរបស់អង្គជំនុំជម្រះតុលាការកំពូលជាមួយភាគីនានា និងតម្រូវការជាក់ស្តែងរបស់រឿងក្តី និងជាការសម្រេចដែលទាមទារឱ្យមានតុល្យភាពដ៏ស្មុគស្មាញរវាងអរូបសម្បត្តិនានា ដើម្បីរៀបចំដីកាសម្រាប់សំណុំរឿងជាក់លាក់នីមួយៗ ធ្វើឱ្យដំណើរការនីតិវិធីសវនាការដែលមានភាពខុសគ្នានោះ មាននិយ័តភាពត្រឹមត្រូវ។ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលពិនិត្យមើលឡើងវិញលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងកម្រិតនៃការសម្រេចថា តើអង្គជំនុំជម្រះសាលាដំបូងបានអនុវត្តត្រឹមត្រូវ ឬមិនត្រឹមត្រូវនូវឆន្ទានុសិទ្ធរបស់ខ្លួន នៅក្នុងការផ្តល់មេធាវីឱ្យ Milosevic។

១០. នៅក្នុងការពិនិត្យមើលឡើងវិញនូវការអនុវត្តឆន្ទានុសិទ្ធិនេះ បញ្ហាចោទមិនមែនថាតើតុលាការកំពូលយល់ស្រប ឬមិនយល់ស្រប ជាមួយនឹងសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងនោះទេ ប៉ុន្តែបញ្ហាត្រង់ថា “តើអង្គជំនុំជម្រះសាលាដំបូងបានអនុវត្តត្រឹមត្រូវ ឬមិនត្រឹមត្រូវនូវឆន្ទានុសិទ្ធិរបស់ខ្លួន ក្នុងការចេញសេចក្តីសម្រេចនោះ”។ ដើម្បីអាចតវ៉ានឹងសេចក្តីសម្រេចឆន្ទានុសិទ្ធិមួយ ម្ចាស់បណ្តឹងសាទុក្ខត្រូវបង្ហាញថា “អង្គជំនុំជម្រះសាលាដំបូងសម្រេចខុសដោយខ្លួនឯងលើគោលការណ៍ដែលត្រូវអនុវត្ត ឬច្បាប់ដែលពាក់ព័ន្ធនឹងការអនុវត្តឆន្ទានុសិទ្ធិនេះ” ឬត្រូវបង្ហាញថា អង្គជំនុំជម្រះសាលាដំបូង “[បានដាក់]ទម្ងន់លើការពិចារណាអង្គហេតុមិនពាក់ព័ន្ធ,... ខកខានមិនបានយក

[៣៦] រឿងក្តី *Milosevic តទល់ រដ្ឋអាជ្ញា,* IT 02-54-AR73.7, “សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ជំទាស់ទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងចំពោះការតែងតាំងមេធាវីការពារក្តី” អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០០៤ (“សេចក្តីសម្រេចក្នុងរឿងក្តី *Milosevic*”)។

ទម្ងន់ឬដាក់ទម្ងន់មិនបានគ្រប់គ្រាន់លើការពិចារណាដល់អង្គហេតុពាក់ព័ន្ធ ឬ...មានការភ័ន្តច្រឡំអង្គហេតុ នៅពេលដែលអង្គជំនុំជម្រះសាលាដំបូងអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន" ឬ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងមាន "ភាពមិនសមហេតុផលទាល់តែសោះ ឬភាពអយុត្តិធម៌យ៉ាងច្បាស់ ដែលអង្គជំនុំជម្រះតុលាការកំពូលអាចទាញការសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូង ប្រាកដជាខកខានក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនឱ្យបានត្រឹមត្រូវ"។ នៅក្នុងការអនុវត្ត ប្រភេទនៃកត្តាទាំងនេះ បង្កើតឱ្យមានវិធានសាមញ្ញដូចតទៅ៖ ការអនុវត្តឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង នឹងត្រូវបដិសេធចោល ប្រសិនបើសេចក្តីសម្រេចត្រូវបានតវ៉ា (១)ផ្អែកលើការបកស្រាយមិនត្រឹមត្រូវនៃច្បាប់ជាធរមាន (២) ផ្អែកលើការសន្និដ្ឋានមិនត្រឹមត្រូវទាល់តែសោះទៅលើអង្គហេតុ ឬ (៣) អយុត្តិធម៌ ឬមិនសមហេតុផល ដែលនាំឱ្យមានការរំលោភបំពានឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង។ ក្នុងករណីដែលពុំមានការភ័ន្តច្រឡំផ្នែកច្បាប់ ឬពុំមានការរកឃើញអង្គហេតុដែលភ័ន្តច្រឡំ ដូចនេះវិសាលភាពនៃការពិនិត្យមើលឧទ្ធរណ៍ គឺមានកម្រិត ទោះបីជាអង្គជំនុំជម្រះតុលាការកំពូលមិនជឿជាក់ថា មេធាវីមិនគួរត្រូវផ្តល់ឱ្យ Milosevic ក៏ដោយ ក៏សេចក្តីសម្រេចខាងក្រោមនូវតែមានអនុភាព លុះណាតែសេចក្តីសម្រេចនោះមានភាពមិនសមហេតុផលទាល់តែសោះ ដែលបង្ខំឱ្យមានការសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងខកខានក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនឱ្យបានត្រឹមត្រូវ[៣៧]។

២៦. តាមរយៈការស្វែងរកការណែនាំនៅក្នុងយុត្តិសាស្ត្ររបស់តុលាការអន្តរជាតិ អង្គបុរេជំនុំជម្រះយល់ឃើញថា ការពិនិត្យមើលឡើងវិញនូវដីកាសម្រេច ត្រូវបានកំណត់ត្រឹមកម្រិតថា តើសហចៅក្រមស៊ើបអង្កេតបានអនុវត្តត្រឹមត្រូវ ឬមិនត្រឹមត្រូវនូវឆន្ទានុសិទ្ធិ តាមរយៈការអនុវត្តនូវលក្ខខណ្ឌដែលចែងខាងលើ។ អង្គបុរេជំនុំជម្រះ មិនត្រូវយកការយល់ឃើញរបស់ខ្លួន ទៅជំនួសការយល់ឃើញរបស់សហចៅក្រមស៊ើបអង្កេតទេ។

## ខ. អង្គសេចក្តីលើបណ្តឹងឧទ្ធរណ៍

២៧. SMD គឺជាទិន្នន័យដែលអាចពិនិត្យមើលតាមរយៈ ECCC ZyIMAGE Search Portal ដោយគ្រប់ភាគី និងគ្រប់ផ្នែកទាំងអស់របស់តុលាការ រួមមានផ្នែកគាំពារ[illegible] ដែលមានឯកសារ និងវីដេអូច្រើនជាង១៧.០០០ ដែលមិនទាន់ត្រូវបាន[illegible]

[៣៧] សេចក្តីសម្រេចក្នុងរឿងក្តី *Milosevic*, កថាខណ្ឌ៩-១០ (ជើងទំព័រត្រូវបានលុបចោល)។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE * E.C.C.C / C.E.T.C *

ប៉ុន្តែត្រូវបានអះអាងថា ឯកសារទាំងនេះពាក់ព័ន្ធទៅនឹងការជំនុំជម្រះចំពោះមុខអ.វ.ត.ក។ ពិធីសារSMDចែងថា៖

> "១. ក.ស.ច.ស និងភាគីនានា អាចមាន (ច្បាប់ចម្លងជាឯកសាររឹង/អេឡិចត្រូនិច និងឯកសារសោតទស្សន៍ ដែលជួនកាលឯកសារខ្លះមានចំនួនច្រើន) តាមតម្រូវការ ដែលឯកសារទាំងនេះមិនទាន់ត្រូវបានវិភាគអំពីភាពពាក់ព័ន្ធរបស់វាទៅនឹងសំណុំរឿងនៅឡើយទេ។ នៅពេលគ្មានការវិភាគបែបនេះ ឯកសារទាំងនេះមិនទាន់ត្រូវបានដាក់នៅក្នុងសំណុំរឿង ដើម្បីកុំឱ្យដាក់បន្ទុកមិនត្រឹមត្រូវទៅលើសំណុំរឿង (និងក្រុមអ្នកបកប្រែ)"។ ទោះបីជាយ៉ាងណាក៏ដោយ ភស្តុតាងមួយចំនួនអាចជាភស្តុតាងដោះបន្ទុក/ដាក់បន្ទុកដែលពាក់ព័ន្ធ និងប្រភពនៃឯកសារទាំងនេះគឺមានលក្ខណៈជាចំហ ("Swedish Collection", DC Cam និង Bophana ។ល។)។
>
> ២. ឃ្លាំងផ្ទុកឯកសាររួម (SMD) នឹងបង្កើតឡើងនៅក្នុង ZyImage ដែលក.ស.ច.ស និងភាគីនានា អាចដាក់ឯកសារទាំងនេះ (ជាជាងឯកសារទាក់ទងនឹងការស៊ើបអង្កេតដែលកំពុងបន្តធ្វើដោយ ក.ស.ព ឬការស៊ើបអង្កេតដោយសហចៅក្រមស៊ើបអង្កេត) និងតាមរយៈSMD ភាគីនានាអាចពិនិត្យមើលឯកសារទាំងនោះបាន[៣៨]"។

២៨. ឯកសារដែលមាននៅក្នុងSMD រួមមាន៖

(i) ឈុតនៃឯកសារវីដេអូ នៃព្រឹត្តិការណ៍ដែលបានកើតឡើងក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ

(ii) ឯកសារនានារបស់តុលាការបដិវត្តកម្ពុជា នៅទីក្រុងភ្នំពេញឆ្នាំ១៩៧៩

(iii) ឯកសារកំណត់ហេតុជាច្រើន ដែលបានរៀបចំឡើងដោយរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ

(iv) ឯកសារបទសម្ភាសន៍

(v) ភស្តុតាងវិភាគទាក់ទងនឹងរបបកម្ពុជាប្រជាធិបតេយ្យ

(vi) សម្រង់សារព័ត៌មាន ឯកសារប្រកាសព័ត៌មាន សេចក្តីថ្លែងការណ៍ជាសាធារណៈ សម្រង់នៃឯកសារសង្ខេបពិភពលោករបស់សាជីវកម្មផ្សព្វផ្សាយអង់គ្លេសនៃការផ្សព្វផ្សាយពិភពលោក គ្របដណ្តប់លើកិច្ចការចុងបូព៌ា និងអត្ថបទស្រាវជ្រាវទាក់ទងនឹងរបបកម្ពុជាប្រជាធិបតេយ្យ និងបក្សកុម្មុយនីស្តកម្ពុជា និង

(vii) កម្រងឯកសារពីប្រភពព័ត៌មានទូទៅ របាយការណ៍វិទ្យុ និងរបាយការណ៍ទូរ

* អង្គជំនុំជម្រះសាលាដំបូង PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C C.E.T.C *

---

[៣៨] ពិធីសារឃ្លាំងផ្ទុកឯកសាររួម, អាចមើលបាននៅ៖ http://zylab/Exe/ZyNET.exe?Client=Common+Collection&Init=1&ZyAction=ZyAction

00402881



ព័ត៌មានទាក់ទងនឹងរបបកម្ពុជាប្រជាធិបតេយ្យ និងឯកសារពាក់ព័ន្ធនានា ពីខែមករា ឆ្នាំ១៩៧៥ ដល់ខែមករា ឆ្នាំ១៩៧៩។

២៩. ឯកសារដែលអាចមានព័ត៌មានពាក់ព័ន្ធទៅនឹងការស៊ើបអង្កេតរបស់តុលាការ រួមមាន៖
(i) ការសួរចម្លើយជនសង្ស័យដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ការស្តាប់ចម្លើយជនរងគ្រោះ និងសាក្សីសំខាន់ៗ
(ii) ព័ត៌មានអំពីលក្ខខណ្ឌរស់នៅនៅក្នុងប្រទេសកម្ពុជានៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ
(iii) ព័ត៌មានអំពីរចនាសម្ព័ន្ធ និងការរៀបចំរបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ
(iv) ភស្តុតាងនៃព័ត៌មានឆ្លងឆ្លើយរវាងផ្នែកផ្សេងៗ នៃរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ
(v) ការបោះពុម្ពផ្សាយជាផ្លូវការ ដែលរដ្ឋាភិបាលរបស់កម្ពុជាប្រជាធិបតេយ្យបានធ្វើ និង
(vi) ព័ត៌មានសហកាលគ្របដណ្តប់លើស្ថានភាព នៅក្នុងប្រទេសកម្ពុជាពីដើមទសវត្សរ៍ឆ្នាំ ១៩៧០ ដល់ទសវត្សរ៍ឆ្នាំ១៩៩០។

៣០. អង្គបុរេជំនុំជម្រះកត់សម្គាល់ថា ភាគច្រើននៃឯកសារត្រូវបានសហព្រះរាជអាជ្ញាដាក់បញ្ចូលទៅក្នុងSMD កាលពីថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ រយៈពេលពីរថ្ងៃ ក្រោយថ្ងៃដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះ[៣៩]។ ឯកសារផ្សេងៗទៀត ត្រូវបានដាក់បញ្ចូលទៅក្នុង SMD ដោយសហចៅក្រមស៊ើបអង្កេត។

៣១. ភាគីនានានៃបណ្តឹងឧទ្ធរណ៍នេះ តវ៉ាលើអង្គហេតុដែលថា ឯកសារនៅក្នុងSMD គឺជាឯកសារដាក់តាមវិធាន៥៣(២) នៃវិធានផ្ទៃក្នុង ដូច្នេះសហចៅក្រមស៊ើបអង្កេតមានកាតព្វកិច្ចធ្វើការស៊ើបអង្កេតឯកសារទាំងនោះ។

៣២. អនុលោមតាមវិធាន៥៣(២) នៃវិធានផ្ទៃក្នុង ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ "ត្រូវអមដោយសំណុំរឿង និងសម្ភារៈដទៃទៀត ដែលបានចាត់ទុកថា មានតម្លៃភស្តុតាងដែល

[៣៩] វាត្រូវបានកត់សម្គាល់ថា ដីកាទំនងជាមិនត្រឹមត្រូវ នៅពេលដីកានេះចែងថា ឃ្លាំងផ្ទុកឯកសាររួម អាចចូលមើលបានក្នុងរយៈពេល "ពីរថ្ងៃមុនពេលបើកកិច្ចស៊ើបសួររបស់តុលាការ" ដូចដែលវានិយាយ[illegible]នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ (ដីកាសម្រេច កថាខណ្ឌ១) និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យ[illegible]នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ (ដីកាសម្រេច កថាខណ្ឌ១៤)។

សហព្រះរាជអាជ្ញាមាន រួមទាំងអ្វីៗទាំងអស់ដែលសហព្រះរាជអាជ្ញាបានដឹងថា អាចជាភស្តុតាងដោះបន្ទុកផងដែរ"។ ពាក្យ "សំណុំរឿង" ត្រូវបានកំណត់និយមន័យនៅក្នុងសន្ទានុក្រមនៃវិធានផ្ទៃក្នុងថាជាការសំដៅទៅដល់ "សំណុំឯកសារដែលរួមមានកំណត់ហេតុនៃកិច្ចដែលបានបំពេញ នៅក្នុងអំឡុងពេលនៃការស៊ើបអង្កេតបឋម ឬការស៊ើបសួរ រួមទាំងពាក្យសុំរបស់ភាគី សេចក្តីសម្រេចជាលាយលក្ខណ៍អក្សរនានា និងអ្វីៗដែលជាឧបសម្ព័ន្ធដែលមាននៅក្នុងគ្រប់ដំណាក់កាលនីតិវិធី រួមទាំងកំណត់ហេតុសវនាការផង"។ នៅពេលដែលបកស្រាយឱ្យស្របទៅនឹងនិយមន័យរបស់ពាក្យ "សំណុំរឿង" ដែលមានចែងនៅក្នុងសន្ទានុក្រមពាក្យ "សម្ភារៈដទៃទៀតដែលបានចាត់ទុកថា មានតម្លៃភស្តុតាងដែលសហព្រះរាជអាជ្ញាមាន" ដែលមានចែងនៅក្នុងវិធាន៥៣(២) នៃវិធានផ្ទៃក្នុង ហាក់ដូចជាសំដៅចំពោះឯកសារនានា ជាជាងឯកសារដែលមានរៀបរាប់នៅតាមនិយមន័យនៃពាក្យ "សំណុំរឿង" ដែលសហព្រះរាជអាជ្ញាពិចារណាថាជាភស្តុតាង ដោយសារតែឯកសារទាំងនេះអាចគាំទ្រចំពោះដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរផង ឬជាប្រភេទនៃឯកសារភស្តុតាងដោះបន្ទុកផង។

៣៣. អង្គបុរេជំនុំជម្រះសង្កេតឃើញថា ឯកសារដែលមាននៅក្នុង SMD មិនមែនជាផ្នែកនៃឯកសារ ដែលសហព្រះរាជអាជ្ញាយោង ដើម្បីគាំទ្រដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬជាឯកសារដែលភ្ជាប់ទៅនឹងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ នៅពេលដីកានោះបញ្ជូនទៅសហចៅក្រមស៊ើបអង្កេត ដើម្បីបើកកិច្ចស៊ើបសួរផ្នែកតុលាការទេ។ ទោះបីជាវាមិនច្បាស់ថា តើសហព្រះរាជអាជ្ញាបានពិនិត្យមើលឯកសារនៅក្នុង SMD ដល់កម្រិតណាយ៉ាងណាក៏ដោយ ក៏សហព្រះរាជអាជ្ញាបានបញ្ជាក់ថា ពួកគាត់មិនបានវិភាគឯកសារទាំងនោះទេ។ សហព្រះរាជអាជ្ញាមិនបានសម្រេចថា ឯកសារឬវីដេអូ ដែលមាននៅក្នុង SMD មាន "តម្លៃជាភស្តុតាង"ទេ។ សហព្រះរាជអាជ្ញាបានប្រកាសបន្ថែមថា ពួកគាត់មិនបានដឹងអំពីអត្ថិភាពនៃភស្តុតាងដោះបន្ទុកនៅក្នុងSMDនោះទេ ទោះបីជាពួកគាត់លើកឡើងថា ពួកគាត់មិនអាចបដិសេធលទ្ធភាពនៃការមានភស្តុតាងបែបនេះទេ។ ការដែលថា សហព្រះរាជអាជ្ញាបានដាក់ឯកសារនៅក្នុងSMD គឺមិនមែនមានន័យថា ឯកសារទាំងនោះសុទ្ធតែមានតម្លៃពាក់ព័ន្ធសម្រាប់ការស៊ើបអង្កេតទេ។ សហព្រះរាជអាជ្ញាបានដាក់ឯកសារនេះនៅក្នុងSMD ដោយសារមូលហេតុនៃភាពយុត្តិធម៌ក្នុងការឱ្យសហចៅក្រមស៊ើបអង្កេត និងភាគីទាំងអស់មានឯកសារទាំងនោះដែរ ពីព្រោះសហព្រះរាជអាជ្ញាមានឯកសារទាំង



PRETRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

00402883



នោះ ហើយពួកគាត់យល់ឃើញថា ឯកសារទាំងនោះអាចមានព័ត៌មានពាក់ព័ន្ធទៅនឹងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ[៤០]។

៣៤. ដោយសារហេតុផលទាំងនេះ អង្គបុរេជំនុំជម្រះយល់ឃើញថា ឯកសារដែលមាននៅក្នុង SMD មិនស្ថិតនៅក្នុងវិធាន៥៣(២) នៃវិធានផ្ទៃក្នុងទេ។ សហព្រះរាជអាជ្ញាបានអនុវត្តយ៉ាងត្រឹមត្រូវ តាមរយៈការផ្តល់ជូនឯកសារនេះឲ្យសហចៅក្រមស៊ើបអង្កេត និងភាគីនានាពិនិត្យមើលឲ្យបានម៉ត់ចត់។ ការគ្រាន់តែដាក់ឯកសារបែបនេះ មិនបានបង្កើតកាតព្វកិច្ចសម្រាប់សហចៅក្រមស៊ើបអង្កេត ដើម្បីពិនិត្យមើលឡើងវិញនូវឯកសារនៅក្នុងSMD ដោយសារតែឯកសារដែលមាននៅក្នុងSMD មិនមែនជាផ្នែកនៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមនោះទេ។

៣៥. អង្គបុរេជំនុំជម្រះកត់សម្គាល់ថា អនុលោមតាមវិធាន៥៥(៥) នៃវិធានផ្ទៃក្នុង សហចៅក្រមស៊ើបអង្កេតមានតួនាទីស៊ើបអង្កេតភស្តុតាងដោះបន្ទុក។ ដើម្បីបំពេញកាតព្វកិច្ចនេះ សហចៅក្រមស៊ើបអង្កេតត្រូវពិនិត្យឯកសារនានា និងសម្ភារៈផ្សេងៗទៀត នៅពេលមានមូលហេតុបឋមនាំឲ្យជឿជាក់ថា ឯកសារទាំងនោះអាចជាភស្តុតាងដោះបន្ទុក។ ការពិនិត្យមើលនេះ ត្រូវតែធ្វើឡើងមុនពេលសហចៅក្រមស៊ើបអង្កេតសម្រេចបិទការស៊ើបអង្កេតរបស់ខ្លួន ដោយមិនគិតថា តើសហចៅក្រមស៊ើបអង្កេតអាចមាន ឬមិនមានភស្តុតាងគ្រប់គ្រាន់ ដើម្បីបញ្ជូនសំណុំរឿងនោះទៅជំនុំជម្រះ។ នៅក្នុងករណីនេះ វិធានផ្ទៃក្នុងបង្ហាញថា ជាដំបូងសហចៅក្រមស៊ើបអង្កេតត្រូវតែបញ្ចប់ការស៊ើបអង្កេតរបស់ខ្លួន[៤១] ដែលមានន័យថា សហចៅក្រមស៊ើបអង្កេតបានបញ្ចប់រាល់កិច្ចស៊ើបសួរទាំងអស់ ដែលខ្លួនចាត់ទុកថាចាំបាច់ ដើម្បីបង្ហាញការពិតទាក់ទងទៅនឹងអង្គហេតុដែលចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម[៤២] មុនពេលវាយតម្លៃថា តើការចោទប្រកាន់មានគ្រប់គ្រាន់ ដើម្បីបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ ឬលើកលែងការចោទប្រកាន់[៤៣]។ ការលើកលែងការចោទប្រកាន់អាចធ្វើទៅបានតែបន្ទាប់ពីសហចៅក្រម

---

[៤០] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៧, ឯកសារ D3។

[៤១] វិធាន៦៦(១) នៃវិធានផ្ទៃក្នុង។

[៤២] វិធាន៥៥(១), (២) និង (៥) នៃវិធានផ្ទៃក្នុង។

[៤៣] វិធាន៦៧(១) នៃវិធានផ្ទៃក្នុង។

ស៊ើបអង្កេតបានជូនដំណឹងភាគីនានាថា ការស៊ើបសួររបស់ខ្លួនត្រូវបានបញ្ចប់[៤៤]។ ភាគីនានាមានឱកាសដាក់សំណើសុំបំពេញកិច្ចស៊ើបសួរ[៤៥] ហើយសហព្រះរាជអាជ្ញាបានដាក់ដីកាសន្និដ្ឋានស្ថាពររបស់ខ្លួន ស្នើសុំសហចៅក្រមស៊ើបអង្កេតឱ្យធ្វើការចោទប្រកាន់ជនត្រូវចោទ ឬលើកលែងការចោទប្រកាន់[៤៦]។ ភស្តុតាងដោះបន្ទុក ឬភស្តុតាងដាក់បន្ទុក ត្រូវតែពិចារណាឱ្យស្មើគ្នា នៅពេលសហចៅក្រមស៊ើបអង្កេតសម្រេចថា តើបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ ឬលើកលែងការចោទប្រកាន់។

៣៦. ដោយការសំអាងហេតុថា "កិច្ចស៊ើបសួរអាចបញ្ចប់បាននៅពេលដែលចៅក្រមស៊ើបអង្កេតកំណត់ថាមានភស្តុតាងគ្រប់គ្រាន់សម្រាប់បញ្ជូនជនត្រូវចោទទៅជំនុំជម្រះនោះ"[៤៧] សហចៅក្រមស៊ើបអង្កេតបានមើលរំលងចំពោះកាតព្វកិច្ចបឋមនេះ ក្នុងការបញ្ចប់ការស៊ើបអង្កេតបឋមរបស់ខ្លួន មុនពេលវាយតម្លៃថាតើរឿងក្តីត្រូវបញ្ជូនទៅជំនុំជម្រះ ឬលើកលែងការចោទប្រកាន់។ ជំហានដំបូងនេះ គឺជាជំហានចាំបាច់ដើម្បីធានាថា សហចៅក្រមស៊ើបអង្កេតបានបំពេញកាតព្វកិច្ចរបស់ខ្លួនក្នុងការស្វែងរក និងពិចារណាលើភស្តុតាងដោះបន្ទុក ដែលភស្តុតាងនោះត្រូវបញ្ជូនដូចគ្នាទៅអង្គជំនុំជម្រះសាលាដំបូង។

៣៧. តាមរយៈការបកស្រាយមិនត្រឹមត្រូវនូវកាតព្វកិច្ចរបស់ខ្លួន ក្នុងការស្វែងរកភស្តុតាងដោះបន្ទុក អង្គបុរេជំនុំជម្រះយល់ឃើញថា សហចៅក្រមស៊ើបអង្កេតមានការភ័ន្តច្រឡំផ្នែកច្បាប់។ ដោយពិចារណាលើកាតព្វកិច្ចរបស់សហចៅក្រមស៊ើបអង្កេតក្នុងការស្វែងរកភស្តុតាងដោះបន្ទុកមុនពេលបញ្ចប់ការស៊ើបអង្កេត ដូចដែលបានលើកឡើងខាងលើ អង្គបុរេជំនុំជម្រះនឹងពិនិត្យថា តើមានឬមិនមានមូលហេតុបឋមដើម្បីជឿជាក់ថា SMDអាចមានប្រភេទនៃភស្តុតាងដោះបន្ទុកដែលសហចៅក្រមស៊ើបអង្កេតត្រូវពិនិត្យមើលភស្តុតាងនេះ។

៣៨. ការរៀបរាប់អំពីSMDខាងលើបង្ហាញថា វាអាចមានឯកសារពាក់ព័ន្ធមួយចំនួនទាក់ទងនឹងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ប៉ុន្តែ

[៤៤] វិធាន៦៦(១) នៃវិធានផ្ទៃក្នុង។

[៤៥] វិធាន៦៦(១) នៃវិធានផ្ទៃក្នុង។

[៤៦] វិធាន៦៦(៥) នៃវិធានផ្ទៃក្នុង។

[៤៧] ដីកាសម្រេច កថាខណ្ឌ៦។

មិនមានអ្វីមួយបង្ហាញប្រាប់ជាក់លាក់អំពីវត្តមាននៃភស្តុតាងដោះបន្ទុកនោះទេ។ ការដែលថា សហព្រះរាជអាជ្ញាមិនអាចបដិសេធលទ្ធភាពនៃការអាចមានឯកសារដោះបន្ទុកនៅក្នុង SMD មិនមែនជាការបង្ហាញបឋមដែល SMD អាចមានភស្តុតាងដោះបន្ទុកនោះទេ។

៣៩. នៅពេលដែលមិនមានការបង្ហាញច្បាស់លាស់ដែលថា ឯកសារណាមួយ និង/ឬវីដេអូដែលមាននៅក្នុង SMD អាចជាប្រភេទនៃភស្តុតាងដោះបន្ទុកនោះ អង្គបុរេជំនុំជម្រះយល់ឃើញថា កាតព្វកិច្ចស៊ើបអង្កេតភស្តុតាងដោះបន្ទុក មិនតម្រូវឱ្យសហចៅក្រមស៊ើបអង្កេតពិនិត្យឡើងវិញទាំងអស់ នូវឯកសារដែលមាននៅក្នុងSMDនោះទេ។ នៅក្នុងកាលៈទេសៈទាំងនេះ ការភ័ន្តច្រឡំនៃច្បាប់ដែលបានធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត មិនអាចធ្វើឱ្យអង្គបុរេជំនុំជម្រះ បដិសេធចោលដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ហើយផ្តល់ជូនតាមការស្នើសុំនោះទេ ប៉ុន្តែសំអាងហេតុរបស់សហចៅក្រមស៊ើបអង្កេតនៅក្នុងករណីនេះ ត្រូវតែជំនួសដោយសំអាងហេតុរបស់អង្គបុរេជំនុំជម្រះវិញ។

៤០. សហចៅក្រមស៊ើបអង្កេតបានបដិសេធសំណើសុំដោយផ្អែកលើមូលដ្ឋានថា សំណើសុំមិនបានបំពេញនូវលក្ខខណ្ឌតម្រូវនៃសំណើសុំបំពេញកិច្ចស៊ើបសួរនោះទេ។ ជាពិសេស សហចៅក្រមស៊ើបអង្កេតពិចារណាថា នៅពេលដែលមានតម្រុយយ៉ាងច្រើនលើសលប់ សហចៅក្រមស៊ើបអង្កេត ត្រូវធ្វើការជ្រើសរើស ដូច្នេះសហចៅក្រមស៊ើបអង្កេតត្រូវតែពិនិត្យពិច័យយ៉ាងហ្មត់ចត់ ដោយអព្យាក្រឹត្យ ដើម្បីអាចផ្ទៀងផ្ទាត់ពីភាពត្រឹមត្រូវ និងច្បាស់លាស់នៃសំណើសុំនេះ មុននឹងឆ្លើយតបចំពោះសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ[៤៨]។ សហចៅក្រមស៊ើបអង្កេតបានលើកឡើងថា “ក្រៅតែលក្ខខណ្ឌទម្រង់សុទ្ធសាធ ដែលអាចត្រូវបានបកស្រាយដោយសេរី ការទាមទារឱ្យមានភាពច្បាស់លាស់នៃសំណើសុំ គឺជាកត្តាសំខាន់បំផុត ពីព្រោះវាមានទំនាក់ទំនងជិតស្និទ្ធជាមួយនឹងគោលការណ៍ពន្លឿននីតិវិធី”[៤៩]។ សហចៅក្រមស៊ើបអង្កេតបានបន្ថែមថា “មេធាវីការពារក្តីដែលស្នើសុំឱ្យមានកិច្ចស៊ើបសួរមួយ ត្រូវមានកាតព្វកិច្ចពន្យល់ដល់ចៅក្រម តើអ្វីទៅ “ភាពសមហេតុផលនោះ”[៥០]។ សហចៅក្រមស៊ើបអង្កេតបានបន្ថែមថា “សំណើសុំធ្វើឡើងដោយមេធាវីការពារក្តី និងមិន

[៤៨] ដីកាសម្រេច កថាខណ្ឌ៧។

[៤៩] ដីកាសម្រេច កថាខណ្ឌ៩។

[៥០] ដីកាសម្រេច កថាខណ្ឌ១១។

អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C * C.E.T.C.

ត្រូវបានវិនិច្ឆ័យថាត្រឹមត្រូវទេ ប្រសិនបើវាមានគោលបំណងតែមួយគត់ គឺប្រាថ្នាឱ្យស្វែងរកភស្តុតាងទាំងអស់"[៥១]។ សហចៅក្រមស៊ើបអង្កេតយល់ឃើញបន្ថែមថា សំណើសុំនេះមិនបានបំពេញលក្ខខណ្ឌទាមទារគ្រប់គ្រាន់ទេ ពីព្រោះវាជាសំណើសុំសហចៅក្រមស៊ើបអង្កេតឱ្យ "ពិនិត្យមើល *ឯកសារទាំងអស់* ដែលដាក់នៅក្នុង SMD" ហើយសហមេធាវីការពារក្តីមិនបានពន្យល់ឱ្យបានច្បាស់លាស់នូវមូលហេតុ ដែលសហមេធាវីយល់ថាសំណើសុំនេះសមហេតុសមផល[៥២]។ សហចៅក្រមស៊ើបអង្កេតពិចារណាថា ដោយសារភាពខ្វះខាតនូវភាពច្បាស់លាស់ ការឆ្លើយតបជាវិជ្ជមានចំពោះសំណើសុំ ប្រាកដជាធ្វើឱ្យនីតិវិធីមានការយឺតយ៉ាវ និងដោយមិនត្រឹមត្រូវ[៥៣]។

៤១. ភាគីតវ៉ានឹងអង្គហេតុដែលថា សំណើសុំបានបំពេញលក្ខខណ្ឌទាមទារគ្រប់គ្រាន់ ហើយថាសហចៅក្រមស៊ើបអង្កេតបានអនុវត្តនូវបទដ្ឋានត្រឹមត្រូវចំពោះករណីនេះ។

៤២. អង្គបុរេជំនុំជម្រះកត់សម្គាល់ថា វិធាន៥៨(៦) នៃវិធានផ្ទៃក្នុងចែងថា សំណើដែលស្នើសុំដោយជនត្រូវចោទក្រោមវិធាននេះ ដែលរួមទាំងសំណើសុំឱ្យប្រមូលភស្តុតាង ត្រូវ "ធ្វើជាលាយលក្ខណ៍អក្សរដោយមានបញ្ជាក់មូលហេតុពិតប្រាកដ"។ វិធាន៥៥(១០) នៃវិធានផ្ទៃក្នុង ដែលមានលក្ខណៈទូទៅជាង អនុញ្ញាតឱ្យភាគីទាំងអស់ស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេត "បំពេញកិច្ចស៊ើបសួរណាមួយ ដែលខ្លួនយល់ឃើញថាមានប្រយោជន៍ដល់ការស៊ើបសួរ" ដោយមិនមានចែងឱ្យច្បាស់អំពីការបញ្ជាក់សំអាងហេតុ ដូចមានចែងនៅក្នុងវិធាន៥៨(៦) នៃវិធានផ្ទៃក្នុង។ ទាំងវិធាន៥៨(៦) និងវិធាន៥៥(១០) នៃវិធានផ្ទៃក្នុងចែងថា សហចៅក្រមស៊ើបអង្កេតត្រូវចែងនូវដីកាសម្រេច ដែលមានសំអាងហេតុនៅពេលសហចៅក្រមស៊ើបអង្កេតបដិសេធសំណើសុំបំពេញកិច្ចស៊ើបសួរ។

៤៣. អង្គបុរេជំនុំជម្រះយល់ឃើញថា បទប្បញ្ញត្តិវិធាន៥៥(១០) នៃវិធានផ្ទៃក្នុង ចែងមិនច្បាស់ថា តើវិធាននេះត្រូវយកមកអនុវត្តស្របគ្នានឹងវិធាន៥៨(៦) នៃវិធានផ្ទៃក្នុង។ បើតាមវិធាន៥៥(១០)នេះ ភាគីដែលដាក់សំណើសុំត្រូវកំណត់ឱ្យច្បាស់នូវការស្នើសុំបំពេញកិច្ច

---

[៥១] ដីកាសម្រេច កថាខណ្ឌ៨។

[៥២] ដីកាសម្រេច កថាខណ្ឌ៩ និង ១១។

[៥៣] ដីកាសម្រេច កថាខណ្ឌ៩។

ស៊ើបសួរ និងរៀបរាប់មូលហេតុ ដែលភាគីស្នើសុំយល់ឃើញថា មានភាពចាំបាច់សម្រាប់ដឹកនាំការស៊ើបអង្កេត[៥៤]។ ករណីនេះអនុញ្ញាតឱ្យសហចៅក្រមស៊ើបអង្កេតវាយតម្លៃថា តើសំណើសុំពាក់ព័ន្ធក្នុងការបង្ហាញការពិត និងផ្តល់សំអាងហេតុនៅក្នុងសេចក្តីសម្រេចរបស់ខ្លួន។ ដូចដែលបានលើកឡើងដោយសហចៅក្រមស៊ើបអង្កេត លក្ខខណ្ឌតម្រូវ ត្រូវតែគោរពតាម ដែលលក្ខខណ្ឌតម្រូវឱ្យសំណើសុំបំពេញកិច្ចស៊ើបសួរ មានលក្ខណៈច្បាស់លាស់គ្រប់គ្រាន់ និងមានភាពពាក់ព័ន្ធ ដើម្បីធានាថា ដំណើរការនីតិវិធីមិនត្រូវបានពន្យារពេលដោយមិនត្រឹមត្រូវ និងសិទ្ធិរបស់ជនត្រូវចោទក្នុងការទទួលបានការជំនុំជម្រះក្នុងពេលសមស្របមួយ ដោយគោរពតាមមាត្រា១៤ នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងវិធាន២១(៤) នៃវិធានផ្ទៃក្នុង។

៤៤. អង្គបុរេជំនុំជម្រះសង្កេតឃើញថា មេធាវីការពារក្តីអាចពិនិត្យមើលឯកសារ និងវីដេអូទាំងអស់ដែលមាននៅក្នុង SMD និងអនុញ្ញាតឱ្យស្នើសុំបំពេញកិច្ចស៊ើបសួរ ប៉ុន្តែសហមេធាវីការពារក្តីក៏ត្រូវមានកាតព្វកិច្ចចាត់ចែង នៅក្នុងរបៀបមួយដែលនឹងមិនពន្យារពេលដល់ដំណើរការនីតិវិធី ជាពិសេសដោយធានាថា សំណើសុំមានលក្ខណៈច្បាស់លាស់គ្រប់គ្រាន់ ក្នុងការបង្ហាញយ៉ាងច្បាស់ទៅសហចៅក្រមស៊ើបអង្កេតអំពីចំណុចអ្វីដែលសហចៅក្រមស៊ើបអង្កេតគួរស្រាវជ្រាវ និងដោយសារមូលហេតុអ្វីបានជាសំណើនេះគួរយកមកធ្វើការស៊ើបអង្កេត[៥៥]។

---

[៥៤] ប្រព័ន្ធបារាំង និងប្រព័ន្ធកម្ពុជាត្រូវបានប្រើដើម្បីជួយដល់អង្គបុរេជំនុំជម្រះក្នុងការបកស្រាយវិធាន៥៥(១០) នៃវិធានផ្ទៃក្នុង ជាពិសេសនោះគឺមានឯកសារយោងដូចខាងក្រោមនេះ៖ មាត្រា១៣៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, មាត្រា៨២-១ នៃក្រមនីតិវិធីព្រហ្មទណ្ឌបារាំង, François-Louis COSTE, *Chambre de l'instruction, Appel et saisine directe ou « Appel par défaut », Rép. Pén. Dalloz*, Décember 2006, កថាខណ្ឌ ១៩២។ Cour d'appel de Limoges, ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៣។ Cour d'appel de Besançon, ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០១។ C. GUÉRY, *Instruction Préparatoire, Droits des parties, Rép. pén. Dalloz* , ខែមករា ឆ្នាំ២០០៨, កថាខណ្ឌ៥៥៧។

[៥៥] លក្ខខណ្ឌវិនិច្ឆ័យស្រដៀងគ្នានេះត្រូវបានអនុវត្តដោយតុលាការអន្តរជាតិនានា នៅពេលទាក់ទងទៅនឹងសំណើសុំបង្ហាញភស្តុតាងដោះបន្ទុក៖ រឿងក្តី *រដ្ឋអាជ្ញា តទល់ Blaskic,* IT-95-14-PT, "សេចក្តីសម្រេចលើការបង្ហាញភស្តុតាងដោះបន្ទុក" អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ១៩៩៧។ រឿងក្តី *រដ្ឋអាជ្ញា តទល់ Blaskic,* IT-95-14, "សេចក្តីសម្រេចលើពាក្យសុំរបស់ម្ចាស់បណ្តឹង ស្នើសុំបង្ហាញភស្តុតាង ការផ្អាក ឬពន្យារ[illegible] ដាក់សារណា និងការដាក់ឯកសារបន្ថែម", អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០[illegible]។ [illegible] **សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំង[illegible] ឯកសាររួម**

PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRÉLIMINAIRE

៤៥. អង្គបុរេជំនុំជម្រះយល់ឃើញថា សហចៅក្រមស៊ើបអង្កេតបានផ្តល់សំអាងហេតុត្រឹមត្រូវដែលថា សំណើសុំត្រូវតែមានលក្ខណៈច្បាស់លាស់គ្រប់គ្រាន់ និងពាក់ព័ន្ធទៅនឹងការបង្ហាញការពិត។ អង្គបុរេជំនុំជម្រះយល់ឃើញថា សេចក្តីសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេតដែលថា សហមេធាវីការពារក្តីមិនបានបំពេញកាតព្វកិច្ចនេះ ដូចមានចែងនៅក្នុងកថាខណ្ឌ៩ និង១១ នៃដីកាសម្រេចរបស់ខ្លួន គឺជាការអនុវត្តត្រឹមត្រូវផ្នែកច្បាប់ និងឆន្ទានុសិទ្ធិរបស់ខ្លួន។ ផ្ទុយនឹងអ្វីដែលអះអាងដោយសហមេធាវីការពារក្តី សហចៅក្រមស៊ើបអង្កេតមិនបានផ្អែកលើសិទ្ធិរបស់ជនត្រូវចោទ ក្នុងការទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេលមិនត្រឹមត្រូវទេ ដើម្បីជាសំអាងហេតុក្នុងការបដិសេធសំណើសុំបំពេញកិច្ចស៊ើបសួរទេ ប៉ុន្តែការយោងរបស់សហចៅក្រមស៊ើបអង្កេតទៅលើសិទ្ធិជាសារវ័ន្តនេះ គឺដើម្បីពន្យល់អំពីភាពសំខាន់របស់សំណើសុំបំពេញកិច្ចស៊ើបសួរ ដែលត្រូវមានភាពច្បាស់លាស់ និងពាក់ព័ន្ធទៅនឹងការបង្ហាញការពិត។ អង្គបុរេជំនុំជម្រះកត់សម្គាល់បន្ថែមថា ទឡ្ហីករណ៍ដែលសហមេធាវីការពារក្តីលើកឡើងថា សហចៅក្រមស៊ើបអង្កេតមិនបានគិតគូរដល់ការបោះបង់សិទ្ធិដែលចុះហត្ថលេខាដោយ អៀង សារី គឺជាទឡ្ហីករណ៍មិនត្រឹមត្រូវដោយសារតែលិខិតបោះបង់សិទ្ធិបានចុះនៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៩ ហើយបានចុះហត្ថលេខា ក្រោយពេលសហចៅក្រមស៊ើបអង្កេតបានចេញដីកាសម្រេចរបស់ខ្លួន រួចទៅហើយ។

---

*រដ្ឋអាជ្ញា តទល់ Delalic* ,IT-96-21-T, សេចក្តីសម្រេចលើសំណើរបស់ជនជាប់ចោទ Hzim Delic ស្របតាមវិធាន៦៨ សុំព័ត៌មានដោះបន្ទុក, អង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី២៤ ខែមិនា ឆ្នាំ១៩៩៧។ *រឿងក្តី Nahimana តទល់ រដ្ឋអាជ្ញា*, ICTR-99-52-A, សេចក្តីសម្រេចលើបណ្តឹងរបស់ Ferdinand Nahimana ដើម្បី[illegible] ធាតុផ្សំដែលរដ្ឋអាជ្ញាមាន និងធាតុផ្សំចាំបាច់ ដើម្បីការការពារកូនក្តីប្តឹងឧទ្ធរណ៍ និងក្នុងគោលដៅដើម្បី[illegible] បញ្ជីក្នុងការស៊ើបអង្កេតបន្ថែមក្នុងដំណើរការបណ្តឹងឧទ្ធរណ៍, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៦។

00402889

០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ២៥)

លេខ/No: D164/3/6

**ដូច្នេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆន្ទ ៖**

១) បណ្តឹងឧទ្ធរណ៍នេះ អាចទទួលយកបាន។

២) ដីកាសម្រេចត្រូវតម្កល់ទុក ដោយសំអាងហេតុដែលមានចែងនៅក្នុងកថាខណ្ឌ៣៥ ដល់៣៩ នៃសាលដីកានេះ ដែលត្រូវជំនួសសំអាងហេតុរបស់សហចៅក្រមស៊ើបអង្កេត។

៣) បណ្តឹងឧទ្ធរណ៍ត្រូវបានបដិសេធចោល។

អនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង សាលដីកានេះបិទផ្លូវតវ៉ា។

ភ្នំពេញ ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៨

**អង្គបុរេជំនុំជម្រះ** **ប្រធាន**

Rowan DOWNING ន័យ ធុល Katinka LAHUIS ហួត វុទ្ធី ប្រាក់ គឹមសាន